# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ៧៤៧/០៩ គ.ជ.ប

## ជម្រាបជូន
## ឯកឧត្តម ហូរ វ៉ាន់ ប្រធានក្រុមប្រឹក្សាគណបក្ស សម រង្ស៊ី រាជធានីភ្នំពេញ

**កម្មវត្ថុ** : ករណីសុំរំកិលលេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខណ្ឌឫស្សីកែវ ខណ្ឌចំការមន ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

**យោង** : -ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
-បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
-លិខិតលេខ ០៨៣/គសរ.ភព ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ ២០០៩ របស់គណបក្ស សម រង្ស៊ី
-លិខិតលេខ ០៨៤/គសរ.ភព ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ ២០០៩ របស់គណបក្ស សម រង្ស៊ី
-លិខិតលេខ ០៨៥/គសរ.ភព ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ ២០០៩ របស់គណបក្ស សម រង្ស៊ី
-អង្គប្រជុំ គ.ជ.ប ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩

តាមកម្មវត្ថុ និង យោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបឯកឧត្តមជ្រាបថា បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខណ្ឌឫស្សីកែវ ខណ្ឌចំការមន ខណ្ឌ៧មករា រាជធានីភ្នំពេញ ជាបញ្ជីផ្លូវការរួចហើយ ដូច្នេះក្នុងដំណាក់កាលនេះ គ.ជ.ប មិនអាចរំកិលលេខរៀងបេក្ខជនបន្ទាប់ឡើងជំនួសបានឡើយ ។ ដោយឡែកយោងតាមចំណុច គ មាត្រា ១៣ នៃ ច.ប.ក ករណីនេះ គ.ជ.ប សម្រេចទទួលយកការស្នើសុំរបស់ឯកឧត្តម ដោយធ្វើការរំកិលលេខរៀងបេក្ខជន ដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅពេលដែល គ.ជ.ប ប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ប្រសិនបើបេក្ខជនដែលស្នើសុំលុបនោះជាប់ឆ្នោត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម មេត្តាជ្រាប ។

សូមឯកឧត្តម ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភាឆ្នាំ២០០៩

**ត.ប. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អគ្គលេខាធិការ**

**ពេជ ចាន់**

**ចម្លងជូន**
- ក្រសួងមហាផ្ទៃ "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ